# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០២១

## ទស្សនកិច្ចរបស់នាវាកងទ័ពជើងទឹកភូមិន្ទអូស្ត្រាលីមកកាន់ប្រទេសកម្ពុជា

នាវា HMAS Anzac កងទ័ពជើងទឹកភូមិន្ទអូស្ត្រាលី បានមកដល់កំពង់ផែក្រុងព្រះសីហនុ នៅព្រឹកនេះ ដើម្បីចាប់ផ្តើមដំណើរទស្សនកិច្ច ដែលមានរយៈពេលបីថ្ងៃ។ នេះជាលើកដំបូងចាប់តាំងពីឆ្នាំ២០១៦ មក ដែលនាវាកងទ័ពជើងទឹកអូស្ត្រាលី បានចូលសំចតនៅកំពង់ផែនៅក្នុងប្រទេសកម្ពុជា។

នាវា HMAS Anzac ជាផ្នែកមួយនៃសកម្មភាពចូលរួមក្នុងតំបន់ នៃនាវាបញ្ជាការរបស់អូស្ត្រាលី ដែលហៅថា កិច្ចខិតខំប្រឹងប្រែងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក "Indo Pacific Endeavour" ។ នៅក្នុងឆ្នាំ ២០២១ នេះ យើងឃើញមានកំលាំងប្រតិបត្តិការតូចមួយរបស់នាវាកងទ័ពជើងទឹកអូស្ត្រាលី ចូលសំចតតាមកំពង់ផែ ធ្វើលំហាត់ហ្វឹកហ្វឺនយោធា ផ្តល់ជំនួយវេជ្ជសាស្ត្រនិងមនុស្សធម៌ ព្រមទាំងផ្លាស់ប្តូរគំនិតថ្មីៗ និងទស្សនវិស័យនានា ស្តីពីបញ្ហាសន្តិសុខជាមួយបណ្តាប្រទេសជាដៃគូរបស់អូស្ត្រាលី នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

ក្នុងពេលប្រារព្ធពិធីនៅឯកំពង់ផែ ឯកឧត្តម Pablo Kang ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំប្រទេសកម្ពុជា បានប្រគល់អំណោយជាសម្ភារៈការពារខ្លួន និងសម្ភារៈវេជ្ជសាស្ត្រ ទាក់ទងនឹងជំងឺកូវីដ ចំនួន ៨០០គីឡូក្រាម ជូនដល់ឯកឧត្តម គង់ វិតាណៈ អភិបាលរងខេត្តព្រះសីហនុ និងឯកឧត្តម ឧត្តមនាវីឯក អ៊ុក សីហា មេបញ្ជាការរងកងទ័ពជើងទឹកខេមរភូមិន្ទ ។

ឯកឧត្តម ឯកអគ្គរាជទូត បានថ្លែងអំណរគុណដល់កម្ពុជាដែលបានធ្វើឲ្យសកម្មភាព Indo-Pacific Endeavour នេះ ទទួលបានជោគជ័យ និងមានប្រសាសន៍បញ្ជាក់ ពីសារសំខាន់នៃ

ការគាំទ្រ និងកិច្ចសហប្រតិបត្តិការទៅវិញទៅមក ក្នុងការដោះស្រាយជំងឺកូវីដ-១៩។ ឯកឧត្តម ឯកអគ្គរាជទូតបានមានប្រសាសន៍ថា "ទស្សនកិច្ចនេះ ពង្រឹងដល់ការប្តេជ្ញាចិត្តរបស់អូស្ត្រាលី ក្នុងការជួយគាំទ្រដល់ការអភិវឌ្ឍ នាពេលអនាគតរបស់ប្រទេសកម្ពុជា រួមមានការស្តារសេដ្ឋកិច្ច និងសុខាភិបាលឡើងវិញពីជំងឺកូវីដ-១៩ និងកិច្ចសហប្រតិបត្តិការយោធាទ្វេភាគីរបស់យើង។"

ឯកឧត្តម ឯកអគ្គរាជទូតមានប្រសាសន៍បន្ថែមថា "ទស្សនកិច្ចនេះកើតឡើងក្នុងសប្តាហ៍ នៃខួបអនុស្សាវរីយ៍លើកទី៣០ នៃការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ដែលបានត្រួសត្រាយផ្លូវបញ្ចប់ជម្លោះជាច្រើនទសវត្សរ៍ នៅក្នុងប្រទេសកម្ពុជា។ កិច្ចព្រមព្រៀង នេះនាំឲ្យមាន អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិក្នុងប្រទេសកម្ពុជា ដែលមានកង ទ័ពអូស្ត្រាលី ជាបុរស និងស្ត្រីជាច្រើនរូប បានចូលរួមបំពេញការងារ ប្រកបដោយកិត្តិយស។"

ក្នុងអំឡុងពេលទស្សនកិច្ចនេះ នាវិកក៏នឹងរៀបចំធ្វើសិក្ខាសាលាតាមប្រព័ន្ធអនឡាញ មួយ ស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខ ជាមួយអ្នកតំណាងខាងកងយោធពលខេមរភូមិន្ទ ផងដែរ ដែលនឹងជាមូលដ្ឋានសំរាប់ការគាំទ្រគោលនយោបាយ និងហិរញ្ញវត្ថុរបស់អូស្ត្រាលី ចំពោះ ដំណើរការជោគជ័យ ក្នុងវេទិកាស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ នៃកិច្ចប្រជុំអាស៊ី-អឺរ៉ុប ដែល ក្រសួងកិច្ចការនារីរបស់ប្រទេសកម្ពុជាបានរៀបចំធ្វើកាលពីសប្តាហ៍មុន ។

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au